ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង៖ ១៣៧/១១-វីឡាយអេបិល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក៖ ម៉ារ សំបូរណា
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ៖ សុខ ម៉ាធឿង

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ ក្រុមហ៊ុន វីឡាយអេបិល សូស អ៊ិនដាសស្ទ្រៀល (ខេមបូឌា)
អាសយដ្ឋាន ៖ ភូមិក្បាលដំរី សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១១ ៦១៤១៥៥ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

១- លោក Michel Hsieh ប្រធានរដ្ឋបាល
២- លោក ព្រឿង តិចសេង រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - សហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា
- សហជីពដើម្បីកម្មករកម្ពុជា នៃក្រុមហ៊ុន វីឡាយអេបិល
អាសយដ្ឋាន ៖ ផ្ទះលេខ១៨៦អា ផ្លូវលេខ២៧សេ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៨៩ ៦២៦ ៣៨៨ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

១- លោក ហ៊ុយ សម្បត្តិ — ប្រធានសហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា

២- កញ្ញា អោម សុខា — លេខាធិការសហជីពដើម្បីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន

៣- កញ្ញា ស្រឿង សៀកម៉េង — គណៈកម្មការសហជីព

៤- កញ្ញា ថៃ នៅ — គណៈកម្មការសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

-កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនចាក់ចម្រៀងស្តាប់កំសាន្តនៅក្នុងម៉ោងធ្វើការ ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះការទាមទារឱ្យចាក់ចម្រៀងស្តាប់កំសាន្តនៅក្នុងម៉ោងធ្វើការនោះ ក្រុមហ៊ុនសុំយកទៅពិភាក្សាជាមួយថ្នាក់ដឹកនាំក្រុមហ៊ុនសិន ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៩) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១១៥៣ កប/អក/វក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ។

## សវនាការ និង សន្ទេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក ) ។

បញ្ហានៃនីតិវិធី ៖

នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះ នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការ

ដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ដោយបានទទួលលទ្ធផលសះជានឹងគ្នាចំនួន ៥ ចំណុច លើការទាមទារចំនួន ៦ ចំណុច។ ចំណុចមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ តាមរបាយការណ៍ដោះស្រាយវិវាទការងាររួមមិនសះជាលេខ ១១៨៣ កប/អក/វក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងនេះរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១ ចំណុចនេះ នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណា និងដោះស្រាយចំណុចវិវាទនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖ គ្មាន

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន វីឡាយអេប៊ិល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា បានចុះបញ្ជិកា លេខ ២២១៦ ក.ប/វក. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

៣- លិខិតលេខ ១៩០ កប ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ថា សហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត ត្រូវបានចុះបញ្ជិកានៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកានេះតទៅ។

៤- លក្ខន្តិកៈសហជីពដើម្បីកម្មករកម្ពុជា នៃរោងចក្រកាត់ដេរ វីឡាយអេប៊ិល អាណត្តិទី១ បានចុះបញ្ជិកា លេខ ២២១៧ កប/វក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ។

៥- បញ្ជីឈ្មោះកម្មករ-កម្មការិនីនៃរោងចក្រ វីឡាយអេប៊ិល ដែលផ្តិតមេដៃសំណូមពរឱ្យនាយករោងចក្រ

ចាក់ចម្រៀងស្តាប់កំសាន្ត ក្នុងម៉ោងការងារ ។

៦- ពាក្យបណ្តឹងរបស់សហព័ន្ធសហជីពដើម្បីកម្មករកម្ពុជា គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសុំឱ្យលោកប្រធានវិវាទការងារ មេត្តាជួយដោះស្រាយអំពីបញ្ហាវិវាទការងាររួម នៅក្នុងរោងចក្រ វីឡាយអេប៊ិល ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន វីឡាយអេប៊ិល លេខ ១១៥៣ កប/អក/វក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន វីឡាយអេប៊ិល ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៧៦២ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៧៦៣ កប/អក/វក/លកអ. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន វីឡាយអេប៊ិល ចាប់ផ្តើមដំណើការនៅក្នុងឆ្នាំ២០០៥ ដោយបច្ចុប្បន្នមានជួលបុគ្គលិកចំនួន ២១០០ នាក់ ។
- នៅក្នុងក្រុមហ៊ុននេះ មានសហជីពចំនួនប្រាំ គឺ សហជីពយុវជនខ្មែរ សហជីពកម្មករនិយោជិត សហជីពឯករាជ្យ និងប្រជាធិបតេយ្យ សហជីពការងារកម្មករកម្ពុជា និងសហជីពដើម្បីកម្មករកម្ពុជា ។ សហជីពដើម្បីកម្មករកម្ពុជា ជាដើមបណ្តឹងក្នុងសំណុំរឿងនេះ មានសមាជិកចំនួន ៤០០ នាក់ ។ សហជីពនេះពុំទាន់មានវិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតទេ ។

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកបើកចម្រៀងនៅក្នុងម៉ោងធ្វើការ ដើម្បីឱ្យកម្មករនិយោជិតស្តាប់

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់ទាមទារឱ្យនិយោជកបើកចម្រៀងនៅក្នុងម៉ោងធ្វើការ ឬ នៅពេលសម្រាកអាហារថ្ងៃត្រង់ ដើម្បីឱ្យកម្មករនិយោជិតស្តាប់ ពីព្រោះថា វាអាចជួយឱ្យពួកគាត់បំបាត់ភាពអផ្សុក និងភាពងងុយគេង ។

- ភាគីនិយោជកបញ្ជាក់ថា មិនអាចរៀបចំចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់តាមការទាមទារបានទេ ដោយហេតុថា មិនមានច្បាប់ណាតម្រូវឱ្យនិយោជកធ្វើដូច្នោះ។
- ភាគីទាំងពីរមិនធ្លាប់មានកិច្ចព្រមព្រៀង ឬការអនុវត្តកន្លងមកស្តីពីការចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់នោះទេ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

ចំណុចវិវាទ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចម្រៀងនៅក្នុងម៉ោងធ្វើការ ឬ នៅពេលសម្រាកអាហារថ្ងៃត្រង់

នៅក្នុងករណីនេះ កម្មករនិយោជិតទាមទារឱ្យនិយោជកចាក់ចម្រៀងនៅក្នុងម៉ោងធ្វើការ ឬនៅពេលសម្រាកអាហារថ្ងៃត្រង់ ឱ្យកម្មករនិយោជិតស្តាប់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលកត់សម្គាល់ឃើញថា ចំណុចវិវាទដូចគ្នានេះ ធ្លាប់ត្រូវបានក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយម្តងរួចមកហើយ ដោយចេញជាសេចក្តីបង្គាប់នៅក្នុងសំណុំរឿងលេខ ២៤/១០-វីឡាយអេបិល នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១០។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងសម្រេចលើចំណុចវិវាទនេះម្តងទៀតដែរ ឬទេ?

ផ្អែកតាមគោលការណ៍ "អាជ្ញាអស់ជំនុំ (*Res Judicata*)" គឺជាគោលការណ៍ផ្លូវច្បាប់ ដែលសំណុំរឿងមួយត្រូវបាននាំមកដោយភាគីវិវាទដដែល ទៅលើចំណុចវិវាទដដែលមកកាន់អង្គជំនុំជំរះមួយ ហើយអង្គជំនុំជំរះនោះ បានចេញសេចក្តីសម្រេចលើចំណុចវិវាទនោះរួចហើយ អង្គជំនុំជំរះមានឆន្ទានុសិទ្ធិក្នុងការលើកយកវិវាទនេះមកពិចារណា ឬ មិនលើកយកមកពិចារណាសម្រេចម្តងទៀតបាន លើកលែងតែមានច្បាប់ជាធរមានចែងផ្ទុយពីនេះ។

ផ្អែកតាមគោលការណ៍នេះ ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ដោយមិនឃើញមានបទប្បញ្ញត្តិច្បាប់ណាមួយចែងពីបញ្ហានេះទាក់ទងនឹងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូច្នេះ នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចលើចំណុចវិវាទមួយរួចហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានឆន្ទានុសិទ្ធិក្នុងការពិចារណាថា តើត្រូវលើកយកចំណុចវិវាទនោះមកសម្រេចសារជាថ្មីឡើងវិញ ឬទេ (សូមមើលសេចក្តីបង្គាប់នៅក្នុងសំណុំរឿង*លេខ ៤៥/០៧-វិល សិន ហេតុផលចំណុចវិវាទទី២, លេខ ១៤/០៨-ឃ្វីក ស៊ូ ហេតុផលចំណុចវិវាទទី១, លេខ ៦៤/០៩-ស៊ីណូមេក ២ លេខ ៩៥/០៩-តាកហ្វាត ហេតុផលចំណុចវិវាទទី៣ និង ៨១/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី១*)។

ទាក់ទងនឹងគោលការណ៍ "អាជ្ញាអស់ជំនុំ (*Res Judicata* )" នេះដែរ នៅក្នុងសំណុំរឿងលេខ ៤២/០៧-សៅធន័បេ ហេតុផលក្នុងចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា គួរបដិសេធការពិចារណាលើការទាមទាររបស់កម្មករនិយោជិត ប្រសិនបើចំណុចវិវាទនេះ បំពេញលក្ខខណ្ឌចំនួន ៣ គឺ ៖

(១) ភាគីវិវាទធ្លាប់ចូលរួមលើចំណុចវិវាទនេះពីមុនមក

(២) ចំណុចវិវាទដែលធ្លាប់នាំមកក្រុមប្រឹក្សាអាជ្ញាកណ្តាល និង

(៣) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើអង្គសេចក្តីចប់សព្វគ្រប់។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងដដែលបានលើកឡើងបន្ថែមទៀតថា គោលបំណងនៃការបដិសេធការពិចារណាលើចំណុចទាមទារដដែលសារជាថ្មី គឺដើម្បីជៀសវាងមិនឱ្យមានលទ្ធផលផ្ទុយគ្នាចំពោះដំណោះស្រាយវិវាទដដែល និងដើម្បីឱ្យការដោះស្រាយវិវាទ ត្រូវបានបញ្ចប់ដោយមានសេចក្តីសម្រេចមួយជាចុងក្រោយ ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏ឯកភាពលើការបកស្រាយខាងលើដែរ ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា មានលក្ខខណ្ឌមួយនៃគោលការណ៍ "អាជ្ញាអស់ជំនុំ (*Res Judicata* )" មិនបានបំពេញទេ ព្រោះនៅក្នុងសំណុំរឿងនេះ ថ្វីត្បិតតែមានចំណុចវិវាទដូចគ្នាមែន តែភាគីដើមបណ្តឹង គឺសហជីពដើម្បីកម្មករកម្ពុជា មិនមែនសហជីពយុវជនខ្មែរដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿង ២៤/១០-វីឡាយអេប៊ិល ទេ។ ហេតុដូចនេះ គោលការណ៍ "អាជ្ញាអស់ជំនុំ" មិនត្រូវបានយកអនុវត្តនៅក្នុងករណីនេះទេ។ មានន័យថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាសម្រេចលើចំណុចវិវាទនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់ក្នុងម៉ោងធ្វើការ ឬនៅពេលសម្រាកអាហារថ្ងៃត្រង់ ដែរឬទេ?

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរមិនធ្លាប់មានកិច្ចព្រមព្រៀង ឬការអនុវត្តកន្លងមកស្តីពីការចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់នោះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការទាមទារឱ្យនិយោជកចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់ក្នុងម៉ោងធ្វើការ ឬនៅពេលសម្រាកអាហារថ្ងៃត្រង់ខាងលើនេះ មិនមានចែងក្នុងច្បាប់ ការអនុវត្តកន្លងមក ឬក៏កិច្ចព្រមព្រៀងណាមួយរវាងកម្មករនិយោជិត និងនិយោជកឡើយ។ ហេតុនេះ ការទាមទាររបស់កម្មករនិយោជិត ជាវិវាទអំពីផលប្រយោជន៍។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ២៤/១០-វីឡាយអេប៊ិល ហេតុផល ចំណុចវិវាទទី១២*) ។

ជាទូទៅ ចំពោះវិវាទទាក់ទងនឹងផលប្រយោជន៍ ក្រុមប្រឹក្សាអាជ្ញាកណ្តាលតែងតែពិចារណាលើភាពជាតំណាងបំផុតរបស់សហជីព ដែលជាភាគីវិវាទ។ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពដើម្បីកម្មករកម្ពុជាប្រចាំរោងចក្រ វីឡាយអេប៊ិល នេះ មិនទាន់មានភាពជាតំណាងបំផុតនៅឡើយទេ ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធការពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីព ដែលនាំវិវាទការងារនោះមក ជាសហជីពដែលមិនមានភាពជាតំណាងបំផុតនៅក្នុងរោងចក្រ។ (សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល*លេខ ៨១/០៤-អេវើគ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ០៩/០៥-គីន តាយ ហេតុផលចំណុចវិវាទទី២, លេខ ៨៤/០៧-យ៉ុង វ៉ា ២ ហេតុផលចំណុចវិវាទទី១, លេខ ១០៨/០៧-៨ ស្តារ ស្វេតទែរ ហេតុផលចំណុចវិវាទ ទី៣ និងលេខ ១៣៥/០៧-វិល ស៊ិន ហេតុផលចំណុចវិវាទទី ១ និង លេខ ១៤/០៨-ហ្វីក ស៊ូ ហេតុផលចំណុចវិវាទទី៣, លេខ ១០១/០៨-ជី ឌី អឹម ហេតុផលវិវាទទី៣ និង លេខ ៤២/០៩ ហេតុផលចំណុចវិវាទទី២*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់គុណវុឌ្ឍន៍ផ្នែកច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួមក្នុងក្រុមហ៊ុន និងមានសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទអំពីផលប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។

ម្យ៉ាងវិញទៀត ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្តីបង្គាប់នេះ"* ។

ផ្អែកលើប្រការ៤៣ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បើក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបង្គាប់ ដែលដោះស្រាយវិវាទអំពីផលប្រយោជន៍ វានឹងក្លាយជាអនុសញ្ញារួមរយៈពេលមួយឆ្នាំ។ ជាទូទៅ អនុសញ្ញារួមត្រូវបានអនុវត្តចំពោះកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ហើយសិទ្ធិក្នុងការធ្វើកូដកម្មមិនអាចអនុវត្តឡើង សម្រាប់សើរើឡើងវិញនូវអនុសញ្ញារួម នៅពេលដែលអនុសញ្ញារួមនោះមិនទាន់ផុតកំណត់នោះទេ ។ (សូមមើលសេចក្តីបង្គាប់របស់អាជ្ញាកណ្តាល*លេខ ១៥២/០៨-វិលសិន ហេតុផលចំណុចវិវាទទី២)* ។ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពដើម្បីកម្មករកម្ពុជាមិន ទាន់មានសិទ្ធិស្របតាមផ្លូវច្បាប់ក្នុងការនាំវិវាទពីផលប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយទេ លើកលែងតែសហជីពនេះ រួមគ្នាជាមួយសហជីពដទៃច្រើនជាក្រុម ដែលនាំឱ្យមានសមាជិកសរុបលើសពី ៥០ ភាគរយ នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងរោងចក្រ ទើបអាចនាំការទាមទារឱ្យនិយោជកចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់មកក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីធ្វើការពិចារណាបាន ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យនិយោជកចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់ នៅក្នុងម៉ោងធ្វើការ ឬនៅពេលសម្រាកអាហារថ្ងៃត្រង់ ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

ចំណុចវិវាទ ៖ បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ដែលទាមទារឱ្យនិយោជកចាក់ចម្រៀងឱ្យកម្មករនិយោជិតស្តាប់ នៅក្នុងម៉ោងធ្វើការ ឬនៅពេលសម្រាកអាហារថ្ងៃត្រង់ ។

ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ ៖ **ម៉ារ សំបូរណា**

ហត្ថលេខា: ---------------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា: ---------------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល:

ឈ្មោះ ៖ **សុខ ម៉ាឡឿន**

ហត្ថលេខា: ---------------------------------------------